**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.១៧៣ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍដំណាំកសិឧស្សាហកម្ម និងកែច្នៃ) និង កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ព្រមទាំង ការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០០៦ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១០១១ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៧១ ខបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីទំហំ ១.១៧៣ ហិកតា ក្នុងនោះ (១) ទំហំ ១៣,៥ ហិកតា កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហាង អាហារណ៍នីហារណ៍ និងអភិវឌ្ឍដំណាំកសិឧស្សាហកម្ម និងកៃថ្លៃ) និង (២) ទំហំ ១.១៥៩,៥ហិកតា កាត់ចេញពីដីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ស្រុកកំរៀង ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៩២ ហិកតា កាត់ចេញពីដីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកណ្តាល ឃុំអូរដា
- ផ្ទៃដីទំហំ ៣៩៦ ហិកតា កាត់ចេញពីដីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិថ្មីឃុំអូរដា
- កាត់ផ្ទៃដីសរុបទំហំ ៥៨៥ ហិកតា ក្នុងនោះ (១) ទំហំ ១៣,៥ ហិកតា កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហាង អាហារណ៍នីហារណ៍ និងអភិវឌ្ឍ



www.pheakdeylaw.com

ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ) និង (២) ទំហំ ៩៧១,៥ ហិកតា កាត់ចេញពីដីតម្រប ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ **កំពង់ចម្លងក្រោម ឃុំតាក្រី**

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃ (១ &២ )អនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូន ប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកកំរៀង ខេត្តបាត់ដំបង ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៩៦៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជា កម្មសិទ្ធិលើដីឯកជន ៩៦២ ក្បាលដី ជូនប្រជាពលរដ្ឋ ៥៥៧ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅស្រុក កំរៀង ខេត្តបាត់ដំបង **ដែលស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម ៖**

១. ឃុំអូរដា

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៨៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១៧០ គ្រួសារ នៅភូមិថ្មី
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២០៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១០៨ គ្រួសារ នៅ ភូមិកណ្តាល ។

២. ឃុំតាក្រី

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៤៦៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ដីឯកជន ៤៦៨ ក្បាលដី ជូនប្រជាពលរដ្ឋ ២៨៣ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅភូមិ កំពង់ចម្លងក្រោម ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍ សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com